ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លិខិតសំរេចរឿងរដ្ឋប្បវេណី

លេខ : ២៧៣

ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩

-----

សាលដីកា

លេខ : ៨៥

ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក ទៀល មួន ចៅក្រម

៣-លោក ជីវ កេង ចៅក្រម

៤-លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥-លោក យស់ សួខឿន ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើពាក្យបណ្តឹង ចុះថ្ងៃទី ២៤.០២.២០០៣ របស់ឈ្មោះ ស៊ុះ ទូលាស់ "ផ្ទេរសិទ្ធិអោយកូន ឈ្មោះ ទូលាស់ សេន" សុំអោយតុលាការកំពូល បក ស្រាយសាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ របស់ តុលាការកំពូល ។

រវាងដើមចោទ ឈ្មោះ ស៊ុប ស៊ែននី ភេទប្រុស អាយុ ៤៥ ឆ្នាំ ជាតិ ខ្មែរឥស្លាម របររកស៊ី នេសាទ ទីលំនៅសព្វថ្ងៃ ភូមិរកាក្រោម ឃុំសំបួរមាស ស្រុកកំពង់ ចាម ។ ឪពុកឈ្មោះ សើ ស៊ុប "រ" ម្តាយឈ្មោះ ទ្បឹប ស៊ុំ "រ" ។

និង ចុងចម្លើយឈ្មោះ ស៊ុះ ទូលាស់ ភេទប្រុស អាយុ ៧៥ឆ្នាំ ជាតិខ្មែរឥស្លាម របររកស៊ី នេសាទ ទីលំនៅសព្វថ្ងៃ ភូមិរកាក្រោម ឃុំសំបួរមាស ស្រុកកំពង់ចាម ខេត្តកំពង់ ចាម ឪពុកឈ្មោះ ជុំ ស៊ុះ "ស" ម្តាយឈ្មោះ ម៉ើ នោ "ស" ។ ផ្ទេរសិទ្ធិ អោយកូនឈ្មោះ ទូលាស់ សេន ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន ទទឹង ៦ម គុណ ៤៥ម

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០០៣ របស់ឈ្មោះទូលាស់សេន ស្នើសុំបកស្រាយសាលដីការដ្ឋប្បវេណី លេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ របស់ តុលាការ កំពូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៧៣ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៦.១១.៩៧ របស់ដើមចោទឈ្មោះ ស៊ុបវែលគី ប្តឹងទាមទារដីលំនៅដ្ឋាន ទំហំ ៦ម គុណ ៤៩ម ពីឈ្មោះ ស៊ុះ ទូលាស់ ដោយអាងហេតុថា : ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ ៧៩ រហូតមកដល់ឆ្នាំ ១៩៨៩ ខ្លួនបានធ្វើបណ្ណកម្មសិទ្ធិ ។ នៅឆ្នាំ ១៩៩១ ឈ្មោះ ស៊ុះ ទូលាស់ បានមកសុំដីខ្លួនស្នាក់នៅបណ្តោះអាសន្ន ។

បានឃើញសាលក្រមលេខ ១១ "ក" ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារ និង សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ១៦.១១.៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-ទទួលស្គាល់កិច្ចសន្យា ចុះថ្ងៃទី ០៥.០១.៩៧ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-ទទួលស្គាល់សិទ្ធិរបស់ចុងចម្លើយ ឈ្មោះ ស៊ុះ ទូលាស់ ជាអ្នកមានសិទ្ធិលើដី ដែលខ្លួនកំពុងកាន់កាប់ តាមតំនូសបង្ហាញ របស់ការិយាល័យ ភូមិបាលស្រុកកំពង់ចាម ចុះថ្ងៃទី ១៣.០១.១៩៩៩ មានក្បាល ១០,១០ម៉ែត្រ គុណ ៦ម៉ែត្រ ។

៤-ដកហូតប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ដែលដើមចោទបានបង់ទុកមុន និង អោយដើមចោទ បង់ពន្ធសមាមាត្រ មួយភាគរយ ស្មើ ១៣.០០០៛ ។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និង ចុងចម្លើយ បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥.០២.៩៩ របស់ឈ្មោះ ស៊ុប វែលគី ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍ លេខ ៤៩៤ ចុះថ្ងៃទី ២២.៧.៩៩ ដែលមានខ្លឹមសារ និង សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥.០២.៩៩ របស់ឈ្មោះ ស៊ុបវែលគី ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-ទទួលស្គាល់មេធាវីឈ្មោះ លឹម ហ៊ុនម៉ិនវីកន់ ជាមេធាវីការពារក្តី និង ជាតំណាងផ្ទេរសិទ្ធិ របស់ឈ្មោះ ទូ លាស់សេន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមលេខ ១១ "ក" ចុះថ្ងៃទី ២៥.០២.៩៩ របស់តុលាការ

ខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៤-កាត់យកប្រាក់ប្រដាប់ក្តី ដាក់សាលាឧទ្ធរណ៍ គឺ ពន្ធប្តឹង និង ពន្ធចុះបញ្ជីក្តី ចំនួន ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរ តុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខ គូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៧៩ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ស៊ុប វីសនី ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីកា របស់ តុលាការកំពូល លេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ២៧៩ ចុះថ្ងៃទី ០៥.៨.៩៩ របស់លោក ស៊ុប វីសនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ២៧៣ ចុះថ្ងៃទី ២១.៩.៩៩ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក ស៊ុប វីសនី បានបង់ ទុករួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

បង្គាប់អោយលោក ស៊ុប វីសនី បង់ពន្ធលមាមាត្រ តាមការកំណត់ របស់ តុលាការខេត្ត កំពង់ចាម ។

៤-សាលដីកានេះ ប្រកាសនាលវិនាការ ជាសាធារណៈ នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០០ ។

បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី ២៤.០២.២០០៣ របស់ឈ្មោះ ទូ លាស់សេន ស្នើសុំបកស្រាយ សាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ របស់តុលាការ កំពូល ។

បានស្តាប់របាយការណ៍បន្ថែម របស់ ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

-ពាក្យបណ្តឹងរបស់ឈ្មោះ ទូលាស់សេន ត្រឹមត្រូវតាមច្បាប់ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ទូ លាស់សេន នៅពេលជំនុំជំរះឡើងថា ៖

-តុលាការខេត្តកំពង់ចាម ថាខុសលេខសាលដីកា ទាល់តែយកអោយតុលាការកំពូល កែលេខសាលដីកាវិញ ។

-ក្រោយពីបានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយរបស់លោក ទូលាស់សេន ជាតំណាងលោក ស៊ុះ ទូលាស់

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា ពាក្យបណ្តឹងសុំបកស្រាយ កែតម្រូវលេខសាលដីការបស់លោក ស៊ុះ ទូលាស់ ចុះថ្ងៃទី ២៤.០២.២០០៣ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ។ តុលាការកំពូល អាចជំនុំជំរះបាន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ របស់ តុលាការកំពូល មានការខុសឆ្គងផ្នែកសំភារៈ ក្នុងការយល់ឃើញ និង ត្រង់ចំនុចទី២ នៃ សេចក្តីសំរេច ត្រង់លេខ និង កាលបរិច្ឆេទ នៃ សាលដីការដ្ឋប្បវេណី របស់សាលាឧទ្ធរណ៍ តុលាការកំពូល គប្បី ធ្វើការកែតំរូវ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណី របស់សាលាឧទ្ធរណ៍ ដែលតុលាការកំពូល សំរេចតម្កល់ ទុកជាបានការពេញទាំងមូល តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ០៩.៥.២០០០ នោះមានលេខ និង កាលបរិច្ឆេទពិតប្រាកដ គឺ លេខ ៤៨៤ ចុះថ្ងៃទី ២២.៧.៩៩ ពុំមែនលេខ ២៧៣ ចុះថ្ងៃទី ២១.៩.៩៩ ទេ ។

-យល់ឃើញថា ឈ្មោះ ស៊ុប ផែលី បានទទួលដីកាកោះ អោយចូលរួមសវនាការ នេះហើយ ប៉ុន្តែពុំបានមកចូលរួមទេ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះឈ្មោះ ទូលាស់សេន កំបាំងមុខឈ្មោះ ស៊ុបផែលី ប៉ុន្តែចាត់ទុកជាចំពោះមុខ ៖

១-ទទួលពាក្យ សុំកែតម្រូវរបស់លោក ស៊ុះ ទូលាស់ ចុះថ្ងៃទី ២៤.០២.២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-កែតម្រូវលេខ និង កាលបរិច្ឆេទ សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍

ត្រង់ចំនុចទី២ នៃ សេចក្តីសំរេចរបស់សាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០០ និង ក្នុងការយល់ឃើញ របស់តុលាការកំពូល ពីលេខ ១ ២៧៣ ចុះថ្ងៃទី ២១.៩.៩៩ មកលេខ ៤៨៤ ចុះថ្ងៃទី ២២.៩.៩៩ វិញ ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៣ ។